**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥-០១-១៥ ប្រ.ក

# ប្រកាស
## ស្តីពី
## ការដាក់អោយប្រើប្រាស់
## មូលប្បទានប័ត្រគំរូថ្មី

---

**ទេសាភិបាល ធនាគារជាតិ នៃ កម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស-រកម-០១៩៦-២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិ នៃ កម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខជស-រកត-០៣៩៨-៨៥ ចុះថ្ងៃទី១០ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលនៃធនាគារជាតិ នៃ កម្ពុជា
- បានឃើញការចាំបាច់ត្រូវដាក់អោយប្រើប្រាស់នូវមូលប្បទានប័ត្រតាមគំរូថ្មី អោយសមស្របតាមស្តង់ដារអន្តរជាតិ
- តាមសំណើរបស់អគ្គនាយកដ្ឋាន

## សំរេច

**ប្រការ១.-**

ដាក់អោយប្រើប្រាស់មូលប្បទានប័ត្រតាមគំរូបោះពុម្ពថ្មី២ប្រភេទ គឺ មូលប្បទានប័ត្រអតិថិជនសំរាប់ចេញអោយម្ចាស់គណនីនៅធនាគារកណ្តាល និងមូលប្បទានប័ត្រធនាគារ សំរាប់ធនាគារកណ្តាលផ្ទាល់ ក្រោមលក្ខណៈសំគាល់ ដូចមានក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ២.-**

មូលប្បទានប័ត្រទាំង២ប្រភេទ ដែលមានចែងក្នុងប្រការ១ ត្រូវដាក់អោយប្រើជំនួសមូលប្បទានប័ត្រតាមគំរូចាស់ទាំងឡាយរបស់ធនាគារជាតិ នៃ កម្ពុជា។

**ប្រការ៣.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទ និង ក្រោមអាណាព្យាបាលធនាគារជាតិ នៃ កម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ៤.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ២០០១

**ទេសាភិបាល**

ជា ចាន់ត្ថូ

**កន្លែងទទួល :**

- ដូចប្រការ៣

"ដើម្បីអនុវត្ត"

- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន :**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាបជាពត៌មាន"

- នាយកដ្ឋានសេវាកុំព្យូទ័រនៃទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

**ឧបសម្ព័ន្ធ**

## លក្ខណៈសំគាល់មូលប្បទានបត្រថ្មី

---

(ផ្អែកតាមប្រការ១ នៃប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់មូលប្បទានបត្រគំរូថ្មី
លេខ ធ៥០១-៦៥ ប្រក. ចុះថ្ងៃទី ៣០ មិនា ២០០១ របស់ធនាគារជាតិនៃកម្ពុជា)

១- **មូលប្បទានបត្រអតិថិជន** មានលក្ខណៈសំគាល់ដូចតទៅ

**ក- លក្ខណៈទូទៅ :**

- បណ្តោយ១៦៦ម.ម ទទឹង ៨៣ម.ម. ពណ៌ចំបង គឺ ពណ៌ផ្ទៃមេឃ និងពណ៌ត្រួយចេក ។

- នៅប៉ែកខាងលើមូលប្បទានបត្រ ផ្នែកខាងឆ្វេងមានអក្សរខ្មែរ និងអក្សរអង់គ្លេសពណ៌ខៀវ "**ធនាគារជាតិនៃកម្ពុជា**" និង "National Bank of Cambodia" ព្រមទាំងអាស័យដ្ឋាន "ទីស្នាក់ការ ២២-២៤ មហាវិថីព្រះនរោត្តមភ្នំពេញ " និង "22-24 Preah Norodom Blvd, Phnom Penh" ចំណែកឯផ្នែកខាងស្តាំ មានផ្ទៃបោះពុម្ពពណ៌ពងមាន់ជារាងពងក្រពើ ហើយមានអក្សរ "ថ្ងៃ-ខែ-ឆ្នាំ" និង "Date......" នៅពីលើនោះ ។

- នៅប៉ែកកណ្តាលនៃសន្លឹកមូលប្បទានបត្រ ផ្នែកខាងឆ្វេងមានអក្សរខ្មែរ និងអក្សរអង់គ្លេស "បើកឱ្យ/Pay to" និង " ចំនួនទឹកប្រាក់/The sum of" និងមានបន្ទាត់ចំនួនបីខ្សែបន្តពីអក្សរទាំងនោះសំរាប់ចុះចំនួនទឹកប្រាក់ជាអក្សរ ឯផ្នែកខាងស្តាំវិញ មានប្រអប់រាងបួនជ្រុងទ្រវែងមួយដែលខាងក្នុងនោះមានបន្ទាត់មួយផ្តុំឡើងដោយចំណុចពងត្រីជាកន្លែងសំរាប់ចុះចំនួន ទឹកប្រាក់ជាលេខ ហើយមានអក្សរខ្មែរ និងអក្សរអង់គ្លេស "ឬអ្នកកាន់/or Bearer" នៅពីលើប្រអប់ និង "**ហត្ថលេខា**/ Signature" នៅពីក្រោមប្រអប់ ។

- នៅប៉ែកខាងក្រោមនៃសន្លឹកមូលប្បទានបត្រ មានបន្ទាត់ឆ្មារមួយកាត់សន្លឹងពីចុងខាងឆ្វេងដល់ចុងខាងស្តាំ ។ តាមបណ្តោយបន្ទាត់នោះ ផ្នែកខាងឆ្វេង ខាងក្រោមបន្ទាត់មានអក្សរ "មូលប្បទានបត្រលេខ" និង "Cheque" ដែលមានបោះពុម្ពដោយទឹកខ្មៅពណ៌ក្រហម នូវលេខ-មាលានៃសន្លឹកមូលប្បទានបត្រនៅពីមុខនោះ ឯផ្នែកកណ្តាលខាងលើបន្ទាត់មានអក្សរ "*មិនត្រូវចុះហត្ថលេខាក្រោមបន្ទាត់/No Signature below this line*" និងខាងក្រោមបន្ទាត់មានអក្សរ "លេខគណនី" និង "Account No." ជាកន្លែងសំរាប់ចុះឈ្មោះ និងលេខគណនីអតិថិជន ។

ក្រៅពីលក្ខណៈសំគាល់ទូទៅដូចបានរៀបរាប់ខាងលើ នៅលើសន្លឹកមូលប្បទានបត្រ ចាប់ពីចំណុចកណ្តាលទៅខាងឆ្វេង មានរំលេចរូបសញ្ញាធនាគារជាតិនៃកម្ពុជា ដែលមានទំហំប្រហែល 1/3 នៃសន្លឹកមូលប្បទានបត្រ ។

**ខ- <u>លក្ខណៈពិសេស</u> :**

- នៅប៉ែកកណ្តាលនៃសន្លឹកមូលប្បទានប័ត្រ បន្ទាត់ចំនួនបីខ្សែ ដែលតពីមុខអក្សរ "បើកឱ្យ/Pay to" និង " ចំនួនទឹកប្រាក់/The sum of" គឺជាខ្សែបន្ទាត់ផ្គុំឡើងដោយអក្សរតូចល្អិត "NATIONAL BANK OF CAMBODIA" ដែលអាចអានបានពេលដែលឆ្លុះមើលដោយកែវពង្រីក ។

- នៅផ្ទៃកណ្តាលនៃរង្វង់រាងពងក្រពើមានអក្សរ "NBC" បោះពុម្ពដោយទឹកខ្មៅអទិស្សមាន ដែលអក្សរនេះអាចមើលឃើញតែក្រោមរស្មីពណ៌ស្វាយប៉ុណ្ណោះ ។

- នៅក្នុងផ្ទៃទាំងមូលនៃកូនប្រអប់រាងបួនជ្រុងទ្រវែង ដែលសំរាប់ចុះចំនួនទឹកប្រាក់ជាលេខ និងនៅបរិវេណតំនួសបន្ទាត់បីខ្សែ ដែលជាកន្លែងសំរាប់ចុះចំនួនទឹកប្រាក់ជាអក្សរ មានផ្ទៃបោះពុម្ពរាងបួនជ្រុងទ្រវែងពីរដាច់ពីគ្នា ដែលប្រើទឹកខ្មៅអទិស្សមាន ហើយផ្ទៃបោះពុម្ពទាំងពីរនេះ មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយ ។

- លេខ-មាលានៃមូលប្បទានប័ត្រត្រូវបានបោះពុម្ពដោយទឹកថ្នាំពណ៌ក្រហម ដែលមានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយ ។

**<u>២-មូលប្បទានប័ត្រធនាគារ (BANKER'S CHEQUE ) មានលក្ខណៈសំគាល់ដូចតទៅ:</u>**

**<u>ក- លក្ខណៈទូទៅ</u> :**

- បណ្តោយ១៦៦ម.ម ទទឹង ៨៣ម.ម ពណ៌ចំបង គឺ ពណ៌លឿង និងពណ៌ផ្ទៃមេឃ ។

- នៅប៉ែកខាងលើមូលប្បទានប័ត្រ ផ្នែកខាងឆ្វេងមានអក្សរខ្មែរ និងអក្សរអង់គ្លេសពណ៌ខៀវ "**ធនាគារជាតិនៃកម្ពុជា**" និង "National Bank of Cambodia" ព្រមទាំងអាស័យដ្ឋាន "ទីស្នាក់ការ ២២-២៤ មហាវិថីព្រះនរោត្តមភ្នំពេញ " និង "22-24 Preah Norodom Blvd, Phnom Penh" ចំណែកឯផ្នែកខាងស្តាំ មានផ្ទៃបោះពុម្ពពណ៌លឿងជារាងពងក្រពើ ហើយមានអក្សរ "ថ្ងៃ-ខែ-ឆ្នាំ" និង "Date......" នៅពីលើនោះ ។

- នៅប៉ែកកណ្តាលនៃសន្លឹកមូលប្បទានប័ត្រ ផ្នែកខាងឆ្វេងមានអក្សរខ្មែរ និងអក្សរអង់គ្លេស "បើកឱ្យ/Pay to " និង "ចំនួនទឹកប្រាក់/The sum of" និងមានបន្ទាត់ចំនួនបីខ្សែបន្តពីអក្សរទាំងនោះ សំរាប់ចុះចំនួនទឹកប្រាក់ជាអក្សរ ឯផ្នែកខាងស្តាំវិញ មានប្រអប់រាងបួនជ្រុងទ្រវែងមួយដែលខាងក្នុងនោះមានបន្ទាត់មួយផ្គុំឡើងដោយចំណុចពងត្រីជាកន្លែងសំរាប់ចុះចំនួន ទឹកប្រាក់ជាលេខ និងមានអក្សរខ្មែរនិងអក្សរអង់គ្លេស "**ហត្ថលេខាអ្នកទទួលសិទ្ធិ**/ Authorized Signature" នៅពីក្រោម ប្រអប់ ។

- នៅប៉ែកខាងក្រោមនៃសន្លឹកមូលប្បទានប័ត្រ មានបន្ទាត់ឆ្នូតមួយកាត់សន្លឹងពីចុងខាងឆ្វេង ដល់ចុងខាងស្តាំ ។ តាមបណ្តោយបន្ទាត់នោះ ផ្នែកខាងឆ្វេង ខាងក្រោមបន្ទាត់មានអក្សរ "មូលប្បទានប័ត្រលេខ" និង "Cheque" ហើយមានបោះពុម្ពដោយទឹកខ្មៅពណ៌ក្រហម នូវលេខ-មាលានៃសន្លឹកមូលប្បទានប័ត្រនៅពីមុខនោះ ។ ឯផ្នែកកណ្តាលខាងលើបន្ទាត់មានអក្សរ " *មិនត្រូវចុះ ហត្ថលេខាក្រោមបន្ទាត់/No Signature below this line*" ។

ក្រៅពីលក្ខណៈសំគាល់ទូទៅដូចបានរៀបរាប់ខាងលើ នៅលើសន្លឹកមូលប្បទានប័ត្រ ចាប់ពីចំណុចកណ្តាលទៅខាងឆ្វេង មានរំលេចរូបសញ្ញាធនាគារជាតិនៃកម្ពុជា ដែលមានទំហំប្រហែល 1/3 នៃសន្លឹកមូលប្បទានប័ត្រ ។4

## ខ_ <u>លក្ខណៈពិសេស</u> :

- នៅប៉ែកកណ្ដាលនៃសន្លឹកមូលប្បទានប័ត្រ បន្ទាត់ចំនួនបីខ្សែ ដែលគពីមុខអក្សរ " បើកឱ្យ/Payto " និង "ចំនួនទឹកប្រាក់/The sum of" គឺជាខ្សែបន្ទាត់ផ្គុំឡើងដោយអក្សរតូចល្អិត "NATIONAL BANK OF CAMBODIA" ដែលអាចអានបានពេលដែលឆ្លុះមើលដោយកែវពង្រីក ។

- នៅផ្ទៃកណ្ដាលនៃរង្វង់រាងពងក្រពើមានអក្សរ "NBC" បោះពុម្ពដោយទឹកខ្មៅអទិស្សមាន ដែលអក្សរនេះអាចមើលឃើញតែក្រោមរស្មីពណិស្វាយប៊ុណ្ណោះ ។

- នៅក្នុងផ្ទៃទាំងមូលនៃកូនប្រអប់រាងបួនជ្រុងទ្រវែង ដែលសំរាប់ចុះចំនួនទឹកប្រាក់ជាលេខ និងនៅបរិវេណគំនូសបន្ទាត់បីខ្សែ ដែលជាកន្លែងសំរាប់ចុះចំនួនទឹកប្រាក់ជាអក្សរ មានផ្ទៃបោះពុម្ពរាងបួនជ្រុងទ្រវែងពីរដាច់ពីគ្នា ដែលប្រើទឹកខ្មៅអទិស្សមាន ហើយផ្ទៃបោះពុម្ពទាំងពីរនេះ មានចំណាំងពន្លឺក្រោមរស្មីពណិស្វាយ ។

- លេខ-មាលានៃមូលប្បទានប័ត្រត្រូវបានបោះពុម្ពដោយទឹកថ្នាំពណិក្រហម ដែលមានចំណាំងពន្លឺក្រោមរស្មីពណិស្វាយ ។